| Student/Registration Number | | | | | | | | | | | | Centre Number | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|

**2022** PUBLIC EXAMINATION

# Khmer

## Continuers Level

**Wednesday 19 October: 2 pm Australian Eastern Daylight Time**

Reading Time: 10 minutes
Writing Time: 2 hours and 30 minutes

- *You have 10 minutes to read all the papers and to familiarise yourself with the requirements of the questions. You MUST NOT write during this time.*
- *Monolingual and/or bilingual printed dictionaries may be consulted during the reading time and also during the examination.*

## Section 1: Listening and Responding (30 marks)

**Instructions to Students**

1. Allow approximately 40 minutes for Section 1.
2. Write all your answers to the questions in Section 1 in this booklet using black or blue pen. Space is provided for you to make notes.
3. You must answer ALL questions in Part A and Part B.
4. Answer Part A in ENGLISH and Part B in KHMER.
5. Write your student/registration number and the centre number (if required) on the front cover of this booklet.
6. All question booklets will be collected at the end of the examination.

*© SACE Board of South Australia 2022*

**Part A** (Questions 1 to 3)
(15 marks)

---

*Your response will be assessed on how well you:*

- *understand general and specific aspects of texts by identifying and analysing information and convey the information accurately and appropriately.*

---

You will hear THREE texts. Each text will be played twice. There will be a short break between the first and second playings of each text. You may make notes at any time.

Listen carefully to each text and then answer the questions in ENGLISH.

**Marks**

You may make notes in this space. These notes will NOT be assessed.

**Text 1**

1. (a) What is the main purpose of this announcement? **1**

_______________________________________________

_______________________________________________

(b) What specific requests are made in the announcement? **2**

_______________________________________________

_______________________________________________

_______________________________________________

_______________________________________________

Marks

You may make notes in this space. These notes will NOT be assessed.

**Text 2**

2. (a) How politely does the woman speak to the taxi driver? Support your answer with evidence from the text. **2**

(b) What information is the woman asking for? **3**

(c) What evidence in the text indicates that the woman has never visited this city before? **2**

Marks

You may make notes in this space. These notes will NOT be assessed.

**Text 3**

3. (a) Why is the woman interested in her son attending the school that the teacher's daughter attends? **1**

(b) How likely is it that the woman will enrol her son in this school? Support your answer with evidence from the text. **4**

**Part B** (Questions 4 to 6)
(15 marks)

*Your response will be assessed on how well you:*

- *understand general and specific aspects of texts by identifying and analysing information and convey the information accurately and appropriately.*

You will hear THREE texts. Each text will be played twice. There will be a short break between the first and second playings of each text. You may make notes at any time.

Listen carefully to each text and then answer the questions in KHMER.

| | **Marks** | You may make notes in this space. These notes will NOT be assessed. |
|---|---|---|

**Text 4**

4. (a) Where is this presentation taking place? **1**

តើគេធ្វើបទបង្ហាញនេះនៅកន្លែងណា?

___

___

(b) According to the presentation, what is the purpose of performing the *trot* dance? **2**

ដោយយោលទៅតាមបទបង្ហាញ អ្វីដែលជាគោលបំណងនៃការសំដែងរបាំត្រុដិ?

___

___

___

___

**Marks**

You may make notes in this space. These notes will NOT be assessed.

**Text 5**

5. (a) What work does Neary Hin do? **1**

តើកិច្ចការអ្វីដែលកញ្ញានារី ហ៊ិនធ្វើ?

(b) List *four* qualities that Neary Hin thinks are necessary for the job. **2**

ចូរស្រង់គុណសម្បត្តិបួនយ៉ាងដែលនារី ហ៊ិនយល់ថាជាការ
ចាំបាច់សម្រាប់កិច្ចការ?

(c) Why is she doing the job? **3**

ហេតុអ្វីបានជានាងធ្វើកិច្ចការនេះ?

Marks

You may make notes in this space. These notes will NOT be assessed.

**Text 6**

6. (a) What does Donaly initially think about Khmer *prasats*? **2**

តើកាលពីដំបូងដូណាលីយល់យ៉ាងម៉េចដែរចំពោះប្រាសាទខ្មែរ?

(b) Explain how the father changes Donaly's opinion about Khmer *prasats* over the course of the conversation. Use examples from the text to support your answer. **4**

ចូរពន្យល់ថាតើឪពុកដូណាលីប្តូរយោបល់របស់នាងដោយរបៀបណា ចំពោះប្រាសាទខ្មែរក្នុងរយៈពេលសន្ទនា។
ចូរប្រើឧទាហរណ៍ពីអត្ថបទដើម្បីគាំទ្រចម្លើយរបស់អ្នក។

**End of Section 1**

**KHMER (CONTINUERS) EXAMINATION 2022**

**Section 1: Listening and Responding**

**PART A**

***Text 1***

អស់លោកលោកស្រីជាទីមេត្រី! ខ្ញុំបាទឈ្មោះថូឡា ជាហេរញ្ញិកនៃពុទ្ធិកសមាគមខ្មែរ។ ថ្ងៃនេះខ្ញុំបាទសូមស្វាគមន៍អស់លោកលោកស្រីក្នុងពិធីបុណ្យចូលឆ្នាំខ្មែរនៅវត្តធម្មិការាម។ ខ្ញុំបាទសូមអស់លោកលោកស្រីមេត្តាចូលវិភាគទានដោយជ្រះថ្លាសម្រាប់កសាងព្រះវិហារយើង។ យើងនឹងចាប់ផ្តើមពិធីបុណ្យដោយប្រារព្ធពិធីថ្វាយបង្គំព្រះក្នុងពេលកន្លះម៉ោងទៀត។ ក្នុងខណៈនេះ សូមអស់លោកលោកស្រីមេត្តារៀបចំចង្ហាន់នៅក្នុងបន្ទប់បាយសម្រាប់ប្រគេនព្រះសង្ឃ។ សូមអរគុណ។

*Text 2*

អ្នកជិះ: តាក់ស៊ី! ហេឡូលោកពូ ខ្ញុំចង់ទៅសណ្ឋាគារអារុណ។ លោកពូយកប៉ុន្មាន?

អ្នកបើកតាក់ស៊ី សណ្ឋាគារអារុណណាមួយដែលក្មួយចង់ទៅ? អាមួយនៅជិតវត្តភ្នំហ្នឹងអ្ហី?។

អ្នកជិះ: ខ្ញុំអត់ដឹងទេលោកពូ នេះជាអាសយដ្ឋានសណ្ឋាគារ។

អ្នកបើកតាក់ស៊ី អូហ៎! ទៅអាមួយហ្នឹងថ្លៃ២០ដុល្លារអាមេរិកក្មួយ។

អ្នកជិះ: ម៉េចក៏ថ្លៃម្ល៉េះលោកពូ?

អ្នកបើកតាក់ស៊ី ពីព្រោះវាច្រើនតែស្ទះចរាចរនៅក្នុងម៉ោងនេះ
ហើយតឡូវណេះមានគេជួសជុលផ្លូវច្រើនណាស់នៅកន្លែងហ្នឹង។

អ្នកជិះ: អញ្ចឹងក៏បានដែរ យកខ្ញុំទៅចុះ។ សណ្ឋាគារហ្នឹងល្អស្អាក់នៅទេលោកពូ?

អ្នកបើកតាក់ស៊ី ប្រាកដជាល្អ។ តម្លៃថោកគួរសម ហើយនៅជិតអ្វីៗទាំងអស់។
មានតូបលក់ចំណីតាមបណ្ដោយថ្នល់ទាំងថ្ងៃទាំងយប់ច្រើនណាស់
ហើយក៏មានភោជនីយដ្ឋាននៅជិតនោះច្រើនទៀតផង។
ក្មួយអាចទៅដើរលេងកន្លែងផ្សេងៗបានយ៉ាងស្រួល ដូចជាវត្តភ្នំ
សារៈមន្ទីរជាតិនិងផ្សារទួលទំពូងជាដើម។

អ្នកជិះ: ខ្ញុំបានឮគេនិយាយច្រើនណាស់ថា
គេតែងតែទៅផ្សារនោះកាលណាគេមកប្រទេសកម្ពុជា។
ម៉េចក៏ពិសេសអញ្ចឹងលោកពូ?
តើផ្សារនោះនៅឆ្ងាយពីសណ្ឋាគារអារុណទេលោកពូ?

អ្នកបើកតាក់ស៊ី មិនឆ្ងាយទេក្មួយ។ នៅផ្សារនោះ ក្មួយអាចទិញវត្ថុអនុស្សាវរីយ៍ច្រើនប្រភេទ
គ្រឿងតុបតែងផ្ទះ សំលៀកបំពាក់បុរាណខ្មែរ និងរបស់របរផ្សេងទៀតជាច្រើន។

អ្នកជិះ: អ៊ឹម! ការធ្វើដំណើរនេះឃើតមែនទែន។ លោកពូមានប្រសាសន៍ត្រូវណាស់។

*Text 3*

| | |
|---|---|
| ម្ដាយ | ជំរាបសួរលោកគ្រូ។ |
| លោកគ្រូ | បាទ ជំរាបសួរ។ សុខសប្បាយទេ? |
| ម្ដាយ | ចាស ខ្ញុំសុខសប្បាយទេ។ លោកគ្រូជ្រាបស្រាប់ហើយ យើងទើបតែមកប្រទេសអូស្ត្រាលីក្នុងពេលថ្មីៗនេះ។ ខ្ញុំចង់រកសាលាវិទ្យាល័យមួយអោយកូនប្រុសខ្ញុំសម្រាប់ឆ្នាំក្រោយ។ ខ្ញុំបានឮថា សាលារៀនដែលកូនស្រីលោកគ្រូទៅរៀននោះល្អខ្លាំងណាស់។ តើលោកគ្រូយល់ថាខ្ញុំអាចចុះឈ្មោះកូនប្រុសខ្ញុំរៀនថ្នាក់ទី៧នៅសាលាហ្នឹងបានទេ? |
| លោកគ្រូ | អ្នកស្រីអាចចុះឈ្មោះបាន បើសិនជាអ្នកស្រីរស់នៅក្នុង ស្គូល ហ្សូន (school zone)។ |
| ម្ដាយ | សូមទោស តើ ស្គូល ហ្សូន មានន័យយ៉ាងម៉េចលោកគ្រូ? |
| លោកគ្រូ | ស្គូល ហ្សូន គឺជាតំបន់នៅជុំវិញសាលារៀនមួយដែលសាលានោះត្រូវតែទទួលសិស្សដែលរស់នៅក្នុងតំបន់នេះ។ អ្នកស្រីរស់នៅទីណាដែរ? |
| ម្ដាយ | ចាស ខ្ញុំរស់នៅប្រហែលជា២០គីឡូម៉ែត្រពីទីនេះ។ តើខ្ញុំនៅក្នុង ស្គូល ហ្សូន សាលាហ្នឹងទេ? |
| លោកគ្រូ | សូមទោសអត់ទេ ប៉ុន្តែកូនអ្នកស្រីអាចធ្វើតេស្ត ហើយបើសិនជាជាប់ កូនអ្នកស្រីអាចចុះឈ្មោះចូលរៀនសាលានេះបាន។ |
| ម្ដាយ | ល្អណាស់អញ្ចឹង ប៉ុន្តែតើវាជាតេស្តរបៀបណាទៅ? |
| លោកគ្រូ | សាលារៀនបានបង្កើតតេស្តពិសេសដ៏ពិបាកមួយ។ សិស្សដែលបានប្រឡងជាប់អាចចុះឈ្មោះបាន ប៉ុន្តែត្រូវតែរៀនខាងគណិតវិទ្យា វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា។ |
| ម្ដាយ | កូនខ្ញុំវាចង់ក្លាយទៅជាមេធាវី ហើយវាមិនពូកែខាងគណិតវិទ្យានិងវិទ្យាសាស្ត្រទេ។ |

លោកគ្រូ ក្នុងករណីនេះ កុំទៅធ្វើតេស្តអី។ ទោះជាយ៉ាងណាក្តី ខ្ញុំនឹងណែនាំអ្នកស្រីអោយស្គាល់មាតាបិតាមួយចំនួនផ្សេងទៀតដែលអាចជួយអ្នកស្រីរកសាលាល្អអោយកូនអ្នកស្រីបាន។

ម្តាយ ចាំស អរគុណលោកគ្រូច្រើនណាស់។

**PART B**

***Text 4***

សួស្តីមិត្តទាំងអស់គ្នា!

ប្រធានបទនៃបទបង្ហាញរបស់ខ្ញុំនៅថ្ងៃនេះគឺរបាំត្រុដិនៅប្រទេសកម្ពុជា។
ខ្ញុំនឹងរៀបរាប់អំពីប្រធានបទនេះដូចតទៅៈ

ត្រុដិគឺជារបាំប្រជាប្រិយខ្មែរមួយដ៏ពេញនិយមនៅប្រទេសកម្ពុជា។ វាជាទំនៀមទំលាប់របស់ខ្មែរ-មនដែលបានហាត់ហ្វឹកហ្វឺនដោយបុព្វបុរសខ្មែរជាច្រើនរស់នៅក្នុងខេត្តសៀមរាប បាត់ដំបង និង ពោធិ៍សាត់។ ពាក្យ ត្រុដិ ជាពាក្យក្លាយមកពីពាក្យសំស្ក្រឹតដែលមានន័យថា បញ្ចប់។ គេច្រើនតែសំដែងរបាំនេះនៅក្នុងពិធីបុណ្យចូលឆ្នាំខ្មែរម្តងៗដើម្បីជំរុះចោលចង្រៃអាក្រក់ពីឆ្នាំមុន និងអបអរសាទរឆ្នាំថ្មី។

*Text 5*

អ្នកសំភាស	អស់លោកលោកស្រីជាទីមេត្រី ភ្ញៀវរបស់យើងនៅថ្ងៃនេះគឺកញ្ញានារី ហ៊ិន ជាសមាជិកម្នាក់នៃក្រុមដោះមីននៅប្រទេសកម្ពុជា។ ជំរាបសួរនារី!

នារី	ចាស ជំរាបសួរ។

អ្នកសំភាស	តើអ្នកនាងធ្វើការជាអ្នកដោះមីនតាំងពីពេលណាមក?

នារី	ប្រហែលមួយឆ្នាំហើយ។

អ្នកសំភាស	កិច្ចការនេះហាក់ដូចជាពិបាកហើយគ្រោះថ្នាក់ផង។
តើគេត្រូវមានគុណសម្បត្តិយ៉ាងដូចម្តេចដែរដើម្បីធ្វើកិច្ចការនេះអោយបានជោគជ័យ?

នារី	យើងត្រូវតែមានសេចក្តីក្លាហាន អំណត់ធ្មត់ អាចធ្វើការជាក្រុមបានល្អ និងមានដៃនឹងនរផង។

អ្នកសំភាស	នេះជាកិច្ចការរបស់មនុស្សប្រុស កញ្ញាយល់ដូច្នេះទេ?
វាមិនធម្មតាទេដែលអ្នកនាងធ្វើកិច្ចការនេះនៅប្រទេសកម្ពុជា។

នារី	ចាសមែនហើយ ប៉ុន្តែនៅក្នុងជំនាន់នេះ យើងមិនត្រូវគិតយ៉ាងដូច្នេះទេ។
ភេទវាមិនសំខាន់ទេដរាបណាយើងអាចធ្វើកិច្ចការបានល្អដូចគ្នា។
ហើយខ្ញុំអាចធ្វើ
កិច្ចការនេះបាន។

អ្នកសំភាស	តើមានមូលហេតុអ្វីផ្សេងទៀតទេដែលជំរុញអោយកញ្ញាចង់ធ្វើកិច្ចការនេះ?

នារី	ចាស លក្ខខណ្ឌធ្វើការល្អគួរសម។ បៀវត្សក៏សមរម្យ ឯម្ហូបអាហារនិងកន្លែងស្នាក់នៅមិនបាច់បង់លុយទេ។
ប៉ុន្តែសំខាន់ជាងគេនោះគឺមានមនុស្សខ្លះនៅក្នុងតំបន់យើងបានទទួលគ្រោះថ្នាក់ដោយសារគេបានដើរជាន់មីននៅក្នុងចំការរបស់គេ
ដូច្នេះខ្ញុំមិនចង់អោយហេតុការណ៍នេះនឹងកើតមានឡើងចំពោះគ្រួសារអ្នកដទៃទៀតនៅថ្ងៃអនាគតទេ។

អ្នកសំភាស	សូមអរគុណដែលបានចែកចាយរឿងរបស់អ្នកនាង។

*Text 6*

| | |
|---|---|
| ឪពុក | ដូណាលី ក្រោយពីបានមើលប្រាសាទមួយចំនួននៅប្រទេសកម្ពុជារួចមក តើឯងយល់យ៉ាងម៉េចដែរ? |
| ដូណាលី | អត់មានអីច្រើនទេប៉ា វាដូចតែគ្នានៅគ្រប់កន្លែង។ នៅក្នុងហ្នឹងអត់មានអីផង ហើយភាគច្រើនសុទ្ធតែបានបាក់បែកដោយសារព្រៃឈើដុះឬក៏ដោយសារការធ្វេសប្រហែសទូទៅ។ |
| ឪពុក | ឯងដឹងទេ ប្រាសាទខ្លះត្រូវបានគេកសាងឡើងតាំងពីសតវត្សទី១២ម្ល៉េះណា។ ឯងគួរតែគិតថា តើបុព្វបុរសយើងគាត់អាចសាងអាគារថ្មទាំងនេះដែលអាចនៅគង់វង់បានយូរដល់ម្ល៉េះ? ឯងមានឃើញស៊ីម៉ង់ទេ? |
| ដូណាលី | ហ៊ឹម! ខ្ញុំអត់ឃើញមានស៊ីម៉ង់អីនៅចន្លោះថ្មទាល់តែសោះ ជាពិសេសនៅតាមក្លោងទ្វារទាំងឡាយ។ |
| ឪពុក | ចុះអំពីរូបចំឡាក់ដ៏ប្រណីតជាច្រើនវិញនោះ ឯងយល់ថាគេឆ្លាក់ថ្មមុនឬក្រោយពេលគេសង់ប្រាសាទ? |
| ដូណាលី | ខ្ញុំយល់ថាគេឆ្លាក់វាមុន បើមិនដូច្នោះទេ វាមានការពិបាកមែនទែន និងខាតពេលវេលាច្រើននៅពេលណាគេឆ្លាក់ខុសម្តងៗ។ |
| ឪពុក | តើឯងយល់ថាគេប្រើម៉ាស៊ីនល្អៗសម្រាប់សង់ប្រាសាទទេ? |
| ដូណាលី | ខ្ញុំមិនជឿទេប៉ា ប៉ុន្តែវាហាក់ដូចជាគេមិនអាចបន្តុបថ្មច្រើនយ៉ាងនេះបានល្អដោយប្រើដៃទទេបានទេ។ |
| ឪពុក | ហេតុនេះហើយបានជាមនុស្សជាច្រើនជឿថា ប្រាសាទទាំងនេះត្រូវបានគេសាងសង់ឡើងដោយមានជំនួយពីព្រះអាទិទេព។ |
| ដូណាលី | អូហ៎ អញ្ចឹងមែនអីប៉ា! វាអច្ឆរិយៈណាស់ មែនទេប៉ា? ខ្ញុំមានភ័ព្វសំណាងខ្លាំងណាស់ដែលមានវាសនាបានឃើញស្នាដៃដ៏អស្ចារ្យរបស់បុព្វបុរសយើង។ |

| Student/Registration Number | | | | | | | | | | | | Centre Number | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|

**2022 PUBLIC EXAMINATION**

# Khmer

## Continuers Level

## Section 2: Reading and Responding (25 marks)

**Instructions to Students**

1. Allow approximately 1 hour and 10 minutes for Section 2.
2. Write all your answers to the questions in Section 2 in this booklet using black or blue pen. Space is provided for you to make notes.
3. You must answer ALL questions in Part A and Part B.
4. Answer Part A in ENGLISH and Part B in KHMER.
5. Write your student/registration number and the centre number (if required) on the front cover of this booklet.
6. All question booklets will be collected at the end of the examination.

© SACE Board of South Australia 2022

**Part A** (Questions 7 and 8)
(10 marks)

---

*Your response will be assessed on how well you:*

- *understand general and specific aspects of texts (for example, by comparing, contrasting, summarising, and/or evaluating) and convey the information appropriately.*

---

7. Read the text and then answer in ENGLISH the question that follows.

**វ៉ាន់ ម៉ូលីវណ្ណ** – ស្ថាបត្យករទីមួយដ៏ល្បីល្បាញរបស់យើង

លោកវ៉ាន់ ម៉ូលីវណ្ណកើតនៅឆ្នាំ១៩២៦ ក្នុងខេត្តកំពតនៃប្រទេសកម្ពុជា។ គាត់បានទទួលអាហារូបករណ៍ទៅសិក្សានៅទីក្រុងប៉ារីស។

ក្រោយពីបានត្រឡប់មកវិញដោយបានទទួលបរិញ្ញាប័ត្រខាងស្ថាបត្យកម្មនៅឆ្នាំ១៩៥៦មក គាត់បានចាប់ផ្តើមធ្វើការជាស្ថាបត្យករអោយរាជរដ្ឋាភិបាល សាងសង់អាគារសំខាន់ៗជាច្រើននៅទូទាំងប្រទេសរួមមាន វិមានឯករាជ្យ សាលមហោស្រពចតុម្មុខ និងពហុកីឡាដ្ឋានជាតិ។ គេអាចសំគាល់បានយ៉ាងងាយនូវថ្វីដៃរបស់គាត់ដោយបានឃើញមានរាងអក្សរ V នៅក្នុងរចនាសំណង់របស់គាត់។

នៅក្នុងចន្លោះឆ្នាំ១៩៥០ទៅ១៩៦០ គាត់បានធ្វើអោយរាជធានីភ្នំពេញក្លាយទៅជាទីក្រុងមួយដ៏ល្អប្រណីតក្នុងចំណោមទីក្រុងនានាក្នុងតំបន់អាស៊ីប៉ែកអគ្នេយ៍។ ជារឿយៗ គាត់ត្រូវបានគេអោយឈ្មោះថាជា ‘បុរសដែលបានកសាងប្រទេសកម្ពុជា’។

លោកម៉ូលីវណ្ណបានរចនាផ្ទះរបស់គាត់អោយស្របទៅតាមអាកាសធាតុត្រូពិច ដោយគិតគូរយ៉ាងប្រុងប្រយ័ត្នអំពីខ្យល់បក់ចេញចូលផ្ទះ ពន្លឺ និងកន្លែងស្រឡះ។ ផ្ទះរបស់គាត់ត្រូវបានគេស្ងើចសរសើរអំពីលក្ខណៈទាន់សម័យលាយឡំជាមួយនឹងលក្ខណៈបុរាណនៃផ្ទះរបស់គាត់។

លោកម៉ូលីវណ្ណបានចាកចេញពីប្រទេសទៅរស់នៅប្រទេសស្វីសនាឆ្នាំ១៩៧១។ ជាការគួរអោយសោកស្តាយបំផុតដែលស្នាដៃរបស់គាត់ទាំងប៉ុន្មានត្រូវបានគេមិនរវីរវល់នៅក្នុងរបបខ្មែរក្រហម។

QUESTION

**Marks**

(a) What was notable about Molyvann's own house? **2**

(b) Discuss the contribution of Molyvann to Cambodia. Support your answer with evidence from the text. **3**



PLEASE TURN OVER

8. Read the text and then answer in ENGLISH the question that follows.

ថ្ងៃអាទិត្យ ទី៩ ខែតុលា ឆ្នាំ២០២២

ថ្ងៃនេះខ្ញុំបានចំណាយពេលមួយល្ងាចជាមួយលោកតានិងលោកយាយ។

ក្រោយពេលបាយថ្ងៃត្រង់រួច លោកតាមានប្រសាសន៍ថា គាត់ចង់ប្រាប់ខ្ញុំអំពីរឿងដ៏សំខាន់មួយគឺ អំពីមធ្យោបាយដែលគ្រួសារយើងបានមករស់នៅប្រទេសអូស្ត្រាលី។ ខ្ញុំមិនធ្លាប់ដែលបានឮរឿងទាំងមូលពីមុនមកទេ ដូច្នេះខ្ញុំនឹងសរសេរវាទុកខណៈដែលខ្ញុំនៅចាំបាន។ លោកតាអ្នកនិយាយ ប៉ុន្តែលោកយាយបានជួយបន្ថែមខ្លះៗដែរ។

ជីវិតនៅប្រទេសកម្ពុជាកាន់តែយ៉ាប់ទៅៗនៅឆ្នាំ១៩៧៩ដែលជំរុញអោយលោកតាលោកយាយសំរេចចិត្តភៀសខ្លួន។ ពេលនោះគាត់មានកូនតែមួយគត់គឺម្តាយខ្ញុំដែលមានអាយុ៣ឆ្នាំ។ គាត់ទាំងអស់គ្នាបានដើរទាំងយប់ទាំងថ្ងៃចំនួន២ថ្ងៃទម្រាំទៅដល់ទល់ដែនថៃ។ វាជាការលំបាកវេទនាណាស់។ មួយខែក្រោយមក អង្គការមនុស្សធម៌ខាងជនភៀសខ្លួនមួយបានដឹកគាត់ទាំងអស់គ្នាទៅទុកនៅជំរំមួយនៅប្រទេសថៃ។ គាត់បានរស់នៅទីនោះចំនួនមួយឆ្នាំ។ លោកតាបានស្ម័គ្រចិត្តធ្វើការជាភ្នាក់ងារចែកម្ហូប ខណៈដែលលោកយាយមើលថែម្តាយរបស់ខ្ញុំ។

លោកតាចេះភាសាអង់គ្លេសបន្តិចបន្តួច ហើយគាត់បានស្នើសុំគេមករស់នៅប្រទេសអូស្ត្រាលី។ ទីបំផុតគាត់ទាំងអស់គ្នាត្រូវបានគេអនុញ្ញាតអោយមក។ ប៉ុន្តែពេលនោះលោកមាសុងបានចាប់កំណើត។ ជាភ័ព្វសំណាងល្អដែល៣ថ្ងៃក្រោយ មកគាត់ទាំងអស់គ្នាត្រូវបានគេអនុញ្ញាតអោយធ្វើដំណើរតាមយន្តហោះមកប្រទេសអូស្ត្រាលីទោះបីជាលោកមាសុងមិនមានទិដ្ឋាការក៏ដោយ។

នៅប្រទេសអូស្ត្រាលី គាត់ត្រូវស្នាក់នៅក្នុងអាគាររដ្ឋមួយចំនួនមួយខែដើម្បីរៀនភាសាអង់គ្លេសនិងទំនៀមទំលាប់អូស្ត្រាលី។ ក្រោយមកគាត់បានប្តូរមករស់នៅទីក្រុងតូចមួយហើយលោកតារកបានការងារធ្វើមួយរំពេច។

លោកតាមានប្រសាសន៍ថា ខ្ញុំមានសំណាងណាស់ដែលបានចាប់កំណើតនៅប្រទេសអូស្ត្រាលី ដូច្នេះខ្ញុំគួរតែខិតខំរៀនសូត្រអោយខ្លាំងនៅសាលា និងតបស្នងសងគុណដល់មាតាបិតាខ្ញុំ។ បន្ទាប់មកលោកតាបានទៅចូលសំរាន្តថ្ងៃមួយស្របក់ ដូច្នេះខ្ញុំនឹងសួរគាត់បន្ថែមទៀតនៅពេលក្រោយ។

QUESTION

**Marks**

(a) Why and how did the writer's grandparents escape Cambodia? **2**

______________________________________________________________

______________________________________________________________

______________________________________________________________

______________________________________________________________

(b) What has the writer gained from hearing their grandfather speak today? Support your answer with evidence from the text. **3**

______________________________________________________________

______________________________________________________________

______________________________________________________________

______________________________________________________________

______________________________________________________________

______________________________________________________________

**Part B** (Question 9)
(15 marks)

---

*Your response will be assessed on how well you:*
- *demonstrate understanding of the stimulus text*
- *write text that is appropriate and relevant to context, purpose, and audience*
- *structure and sequence information and ideas*
- *manipulate language structures and vocabulary in Khmer.*

---

9. Read the text and then answer the question in approximately 150 words in KHMER.

**សិស្សសាលាមិនគួរធ្វើការទេ**

សិស្សសាលានៅប្រទេសអូស្ត្រាលីមិនគួរធ្វើការមិនពេញម៉ោងពេលកំពុងសិក្សាទេ។ គេទាំងនោះគួរផ្ទង់គំនិតលើការសិក្សារបស់គេដើម្បីអោយបានទទួលពិន្ទុខ្ពស់បំផុតដែលអាចធ្វើទៅបាន។ ការធ្វើការបណ្តើររៀនបណ្តើរវានាំអោយខាតពេលវេលា។ បើសិនជាគេមានពេលទំនេរ គេគួរជួយមាតាបិតារបស់គេដោយមើលថែរក្សាប្អូនៗ ជួយដាំបន្លែ ឬក៏ធ្វើកិច្ចការអ្វីផ្សេងទៀតដែលមានប្រយោជន៍។

មនុស្សខ្លះនិយាយថា ក្មេងត្រូវការធ្វើការដើម្បីរៀននិយាយទាក់ទងជាមួយអ្នកដទៃ។ វាមិនសំខាន់ទេ ហើយវានឹងមានឱកាសពេលក្រោយទៀតនៅពេលដែលក្មេងទាំងនោះធំឡើង។

ម៉្យាងទៀត បើក្មេងធ្វើការ គេនឹងបានទទួលប្រាក់កំរៃ។ ប៉ុន្តែគេនឹងចាយលុយទៅលើទូរស័ព្ទ សំលៀកបំពាក់ ចំណីចំណុក និងឡាន។ វាជាការខាតបង់ឥតអំពើ!

សិស្សសាលាអាចគិតថា គេនឹងបានទទួលបទពិសោធន៍ការងារពេលធ្វើការមិនពេញម៉ោង។ ប៉ុន្តែចំណេះដឹងខាងធ្វើកាហ្វេ រៀបចំតវ៉ាន់ដាក់លើធ្នើ នឹងមិនអាចជួយដល់មុខងារពិតប្រាកដ ដូចជា វេជ្ជបណ្ឌិត មេធាវី ឬវិស្វករឡើយ។

កិច្ចការតែមួយគត់ដែលសិស្សគួរធ្វើគឺកិច្ចការសាលា។

QUESTION

You have read this opinion piece in a Khmer-language newspaper. Write a letter to the editor arguing against the opinion presented.

អ្នកបានអានយោបល់មួយសន្លឹកនេះនៅលើទំព័រសារពត៌មានជាភាសាខ្មែរមួយ។ ចូរអ្នកសរសេរលិខិតមួយផ្ញើទៅចាងហ្វាងនិពន្ធ ដោយបញ្ចេញយោបល់ប្រឆាំងទៅនឹងយោបល់ដែលបានរៀបរាប់។

*You may remove this page from the booklet by tearing along the perforations so that you will have the information in front of you for easy reference.*

You may make notes on this page. These notes will NOT be assessed.

This page is intentionally blank

Question 9

**End of Section 2**

Student/Registration Number | | | | | | | | | | | | Centre Number | | | | | | |

## 2022 Public Examination

# Khmer

## Continuers Level

### Section 3: Writing in Khmer (20 marks)

**Instructions to Students**

1. Allow approximately 40 minutes for Section 3.
2. Write your answer to a question from Section 3 in this booklet using black or blue pen. Space is provided for you to make notes.
3. You must answer ONE question in KHMER.
4. Write your student/registration number and the centre number (if required) on the front cover of this booklet.
5. All question booklets will be collected at the end of the examination.

© SACE Board of South Australia 2022

**Section 3** (Questions 10 to 12)
(20 marks)

---

*Your response will be assessed on how well you:*

- *demonstrate depth of treatment of information, ideas and/or opinions*
- *write text that is appropriate and relevant to context, purpose, and audience*
- *structure and sequence information and ideas*
- *manipulate language structures and vocabulary in Khmer.*

---

Answer ONE question from this section in approximately 250 words in KHMER.

10. Once you turn 18 years of age, you are thinking of moving out to live independently close to the university that you have enrolled in. You want to tell your parents your decision. To help you prepare for the discussion, write what you will say to your parents.

    ដល់ពេលអ្នកមានអាយុ១៨ឆ្នាំ អ្នកគិតថានឹងចាកចេញទៅរស់នៅដោយឯករាជ្យជិតមហាវិទ្យាល័យដែលអ្នកបានចុះឈ្មោះចូលរៀនរួចហើយ។ អ្នកចង់ជំរាបមាតាបិតារបស់អ្នកអំពីសេចក្ដីសម្រេចចិត្តរបស់អ្នក។ ដើម្បីរៀបចំការពិភាក្សាជាមួយគាត់ ចូរអ្នកសរសេរនូវអ្វីដែលអ្នកនឹងជំរាបមាតាបិតាអ្នក។

11. Chantha, one of your female cousins living in Cambodia, is planning to come to Australia next year to undertake her Year 11 studies. She has written a letter to you wanting to know about the school system and the student lifestyle in Australia. Write a letter replying to your cousin.

    ចន្ថា ជីដូនមួយស្រីរបស់អ្នកម្នាក់ដែលរស់នៅក្នុងប្រទេសកម្ពុជាមានគំរោងមកសិក្សាថ្នាក់ទី១១នៅប្រទេសអូស្ត្រាលីឆ្នាំក្រោយ។ នាងបានសរសេរសំបុត្រមួយផ្ញើមកអ្នក ដោយចង់ដឹងអំពីប្រព័ន្ធសាលារៀន និងជីវភាពរស់នៅរបស់សិស្សនៅប្រទេសអូស្ត្រាលី។ ចូរអ្នកសរសេរលិខិតមួយឆ្លើយតបទៅជីដូនមួយរបស់អ្នកវិញ។

12. Imagine that it is 10 years since you finished school and your Khmer language class is holding a reunion. The organiser is producing a booklet about what the classmates have done since then. Write an article for the booklet about the most important moments of your life and your achievements since leaving school.

    ឧបមាថា ១០ឆ្នាំក្រោយពេលដែលអ្នកបានបញ្ចប់ការសិក្សារបស់អ្នកមក ថ្នាក់ភាសាខ្មែររបស់អ្នកបានរៀបចំពិធីជួបជុំគ្នាមួយ។ អ្នកចាត់ចែងពិធីនេះបានបង្កើតកូនសៀវភៅមួយអំពីអ្វីដែលមិត្តរួមថ្នាក់របស់អ្នកបានធ្វើតាំងពីពេលនោះមក។ ចូរអ្នកសរសេរអត្ថបទចុះផ្សាយមួយសម្រាប់កូនសៀវភៅនោះអំពីព្រឹត្តិការណ៍សំខាន់ជាងគេក្នុងជីវិតរបស់អ្នក និងសេចក្ដីសម្រេចគោលបំណងរបស់អ្នក តាំងពីពេលដែលអ្នកបានចាកចេញពីសាលា។

*You may remove this page from the booklet by tearing along the perforations so that you will have the information in front of you for easy reference.*

You may make notes on this page. These notes will NOT be assessed.

This page is intentionally blank

Question Number:



PLEASE TURN OVER

**End of Section 3**